ប្រលោកលោកមនោសញ្ចេតនា

# ស្រមោលស្នេហ៍ចាស់

និពន្ធដោយ
ខនរក្សាចេន្ទ បូណ៏មីរ

ឆ្នាំ២០២០

# អារម្ភកថា

រឿង«ស្រមោលស្នេហ៍ចាស់»នេះគឺជាសាច់រឿងប្រតិដ្ឋមួយដែលខ្ញុំបាននិពន្ធឡើងដើម្បីផ្ដល់ជាគំនិតខ្លះ ដល់មិត្តអ្នកអានជាពិសេសអ្នកដែលកំពុងមានស្នេហា រស់ក្នុងជីវិតគូដើម្បីទុកជាគតិខ្លះក្នុងការពិចារណា។ ស្នាដៃមួយនេះជាស្នាដៃទីពីររបស់ខ្ញុំ បន្ទាប់ពីរឿងអរគុណសង្សារចាស់ ហើយក៏មិនមែនជាស្នាដៃដែលល្អឥតខ្ចោះអីដែរ ប៉ុន្តែខ្ញុំសង្ឃឹមថាស្នាដៃមួយនេះអាចជាទីកំសាន្តនៃអារម្មណ៍របស់អ្នកអាន ជាមិត្តយល់ចិត្ត ឬទីប្រឹក្សារបស់អ្នក និងជាពន្លឺខ្លះនៃដំណោះស្រាយអាចឲ្យអ្នកហ៊ានចាកចេញពីបញ្ហាដែលកំពុងជួបខ្លះៗក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

បើទោះបីជាបានពិនិត្យជាច្រើនលើកច្រើនសារក៏ដោយ ក៏ខ្ញុំជឿជាក់ថានៅតែមានចំណុចខុសឆ្គង ឬការភ្លាំងភ្លាត់ដោយអចេតនា ផ្នែកណាមួយនៃ អក្ខរាវិរុទ្ធ រចនាបទ និងខ្លឹមសារណាមួយជាក់ជាមិនខាន។

អាស្រ័យហេតុនេះខ្ញុំសូមអភ័យទោសទុកជាមុន ហើយសង្ឃឹមថាកំហុសទាំងនោះនឹងត្រូវបានផាត់ចោល

ដោយសេចក្តីអនុគ្រោះពីមិត្តអ្នកអានជាក់ជាមិនខានឡើយ។

ជាចុងក្រោយខ្ញុំសូមគោរពជូនពរមិត្តអ្នកអានឲ្យជួបតែនឹងសេចក្តីសុខគ្រប់ប្រការជានិច្ចនិរន្តន៍តទៅ ជាពិសេសកុំបោះបង់ខ្លួនឯងចោលទោះកាលៈទេសៈណា និងស្រឡាញ់ខ្លួនឯងឲ្យច្រើនៗណា។

ដោយក្តីស្រឡាញ់រាប់អានអំពីខ្ញុំ!

បាត់ដំបង ថ្ងៃពុធទី១៨ខែកញ្ញាឆ្នាំ២០២០

ខន រក្សា(ចន្ទ បូណ៌មី)

# សេចក្តីថ្លែងអំណរគុណ

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖*

*- មនុស្សជាទីស្រឡាញ់ រិន វិចិត្រ ដែលបានផ្តល់កម្លាំងចិត្ត នឹងជួយសម្រួលរឿងនេះតាំងពីចាប់ផ្តើម រហូតបញ្ចប់រួចរាល់។*

*-មិត្តអ្នកអានគ្រប់គ្នាដែលបានគាំទ្រស្នាដៃរបស់ខ្ញុំ។*

*-ស្ថាបនិកនឹងក្រុមការងារស្រមៃប៊ុកដែលផ្តល់ឱកាសដល់ ការចេញផ្សាយស្នាដៃរបស់ខ្ញុំ។*

*បើគ្មានអ្នកទាំងអស់គ្នាទេ ស្នាដៃនេះក៏មិនអាចមាន រូបរាងឡើងបានដែរ។*

# ១

# ឈើកំពូលភ្នំ

ព្រះទិនមណីបានបន្ទាបខ្លួនចុះចូលក្នុងពពកម្តងបន្តិចៗដែលរសាត់ពាសពេញផ្ទៃមេឃលាយទៅដោយពណ៌លឿងទុំ និងក្រហមគួរជាទីគយគន់នៃមនុស្សគ្រប់គ្នា។ចំណែកបក្សីបក្សាដែលបាននាំគ្នាហើយទៅរកចំណីតាមពីព្រលឹម ក៏នាំគ្នាហើរត្រលប់មកវិញទាំងហ្វូងៗចូលកាន់ទ្រនំដើមរបស់ខ្លួននាខ្នងភ្នំព្រោម។ ខណ:នោះដែរ មាននរ:រូបសង្ហាម្នាក់ កំពុងជិះម៉ូតូចុះពីកំពូលភ្នំត្រលប់ទៅផ្ទះវិញ ដោយទុកតែសម្រស់ដ៏ស្រស់ត្រកាលនៃសាយណ្ហាសម័យតែម្នាក់ឯង។

លុះមកដល់ផ្លូវតូចហួសវត្តគោកចកបន្តិចរអ្នកកម្លោះរូបសង្ហាក៏បានបតម៉ូតូចូលផ្ទះ ដើរសំដៅទៅបន្ទប់ តែខណ:នោះក៏មានស្ត្រីចំណាស់ម្នាក់បន្លឺសំឡេងឡើង៖

“បញ្ញា! កូនទើបមកពីណា មើលទៅរៀងហត់ល្ហើយម្លេះ?”

សុខ បញ្ញា ជាឈ្មោះរបស់នរៈរូបសង្ហា ជាកូនកម្លោះតែមួយគត់របស់មីង លក្ខិណា។
"បាទ! ម៉ាក់កូនមិនបានកើតអីទេ"
ចម្លើយហាក់ចាកពីសំណួរម្ដាយ តែមីងក៏ទុកចម្ងល់ក្នុងចិត្ត
"អីចឹង!កូនទៅងូតទឹក រួចចុះមកញ៉ាំបាយជុំគ្នា"
"បាទ! ម៉ាក់"

ម៉ោង១០យប់ទៅហើយ អ្នកកម្លោះនៅអង្គុយដកដង្ហើមធំមុខកុំព្យូទ័របើកកម្មវិធីWordចោលដោយមិនមានសរសេរអ្វីសោះតាមពីឡើងពីអាហារពេលល្ងាចជាមួយគ្រួសារមក។
"ទីង! ទីង!ទីង! សួស្ដីអ្នកទាំងអស់គ្នា ថ្ងៃនេះយើងមានសមាជិកថ្មីមករួមក្រុម គាត់ឈ្មោះទេពី"
"ជម្រាបសួរ! សួស្ដី! រៀមច្បងទាំងអស់គ្នា នាងខ្ញុំឈ្មោះចន្ទ ទេពី សូមការណែនាំ និងរៀនសូត្រពីបងៗផង"
"ដាក់ខ្លួនណាស់ណ៎! ទេពី" (វ៉ាយុ)
វ៉ាយុជាប្រធានក្រុមអ្នកនិពន្ធវ័យក្មេង ដែលបានណែនាំទេពីចូលក្រុមនិពន្ធ។
"សួស្ដី! ទេពី រីករាយណាស់ដែលបានស្គាល់ ខ្ញុំឈ្មោះសុខ បញ្ញា"

អូហូ! ការពិតនរៈរូបសង្ហាយើងជាអ្នកនិពន្ធសោះ cool! មិនធម្មតាទេ សង្ហាហើយជាអ្នកនិពន្ធទៀត។

“បាទ! ជម្រាបសួររៀមច្បង រីករាយដូចគ្នា” (ទេពី)

“ស្រីឬប្រុសហ្នឹង? បានឆ្លើយបាទ” (សីហា)

សីហាជាសមាជិកម្នាក់ក្នុងក្រុមនិពន្ធដែរ។

“ជាប្រុសបាទ! ហិហិហិ’’ (ទេពី)

“ក្បាលខ្ចូចណាស់ ទេពី! មកដល់ភ្លាមក្លូរបងៗភ្លាម” (វ៉ាយុ)

“ហូ...! ម្ចាស់បង មានណា”(ទេពី)

“អត់ទៀតណា! នាំបងវង្វេងអស់ មកឆ្លើយបាទខ្ចូចពូជបុរសអស់” (សីហា)

“ហឹម! គេងហើយ ឈប់លេងក៏បាន” (ទេពី)

“បងៗលលេងតើ មកពីមិនដែលមាននារីក្នុងក្រុម ហិហិហិ!” (វ៉ាយុ)

“មែនហ្នឹង! ប្រញាប់តែងរ” (សីហា)

“ទេពី!អត់បានខឹងទេបាទ តែងងុយហើយ” (ទេពី)

“បាត់ឲ្យស្វាត់ឈឺងបញ្ញា មិនចូលលេងសោះ” (វ៉ាយុ)

“ប្រហែលរៀមច្បងរើសរើងទេពីហើយមើលទៅ” (ទេពី)

“មិនមែនទេ បងបញ្ញាមិនមែនចឹងទេ កូននេះ ឆាប់តែគិតអន់ចិត្តម្នាក់ឯង” (វ៉ាយុ)
“រាត្រីសួស្តី!រៀមច្បងទាំងអស់គ្នា” (ទេពី)
“បាទ! សុបិនល្អ” (វ៉ាយុ និងសីហា)

សំឡេងសារក្នុងTelegramក៏ស្ងាត់ ក្រឡែកមកមើលនារ:យើងវិញ បែបជាព្រៀមក្រំណាស់ មិនដឹងថាពិបាកចិត្ត ខ្វល់ខ្វាយពីរឿងអ្វី?មួយសន្ទុះមកក៏លង់លក់ទៅ។

ពេលព្រឹកសំឡេងមាន់រងាវ នារ:យើងក៏ភ្ញាក់មកបើកមើលសារក្នុងTelegramដែលមិនបានមើលពីយប់ ហើយក៏ចូលទៅឆែកឈ្មោះមាណវីរូបស្រស់ដែលមិនមានចំណុចទាស់។ ហើយប្រញាប់ចូលទៅរកក្នុងអាខោន Facebook ក៏addទៅតែម្តង អីយ៉ា! កំលោះយើងឃើញស្ងៀមស្ងាត់ សោះកព្រោះអីចឹងចិត្តខ្លាំងរកឈ្មោះបាន ហើយaddទៅភ្លាមតែម្តងគោលបំណងអ្វីទៅណ៎? នាំឲ្យកម្លោះសង្ហាហ៊ានaddផមាណវី? ចាំសួរសុខ បញ្ញា ខ្លួនឯងទៅ ចន្ទ បូណ៌មីក៏អត់ដឹងដែរ...តែវ! តែគេអត់ទទួលទេមួយអាទិត្យហើយ។

នរណាaddមកចេះ ដូចធ្លាប់ស្គាល់? អូ! រៀមច្បង នៅក្នុងក្រុមនិពន្ធតើ យូហើយហ្នឹងភ្លេចទទួល (ទេពី) ចំណែកបញ្ញារិញ ចូលចិត្តផុសតែកំណាព្យ និងអត្ថបទស្នេហាខូចចិត្តស្ទើររាល់ថ្ងៃៗ ខូចចិត្តរឿងស្នេហាហ្មងប៉ិហ្នឹង ហេ!ហេ!

# ២

# និស្ស័យ

## ចន្ទ បូណ៌មី

ថ្ងៃនេះពេញបូរមី ព្រះទិនករហៀបនឹងអស្ដង្គតទៅ មិនយូរប៉ុន្មានព្រះចន្ទពេញវង់ក៏រះឡើង ដើម្បីបញ្ចាំងរស្មីមកពសុធាពាសពេញជម្ពូទ្វីបទាំងមូល។គ្រានោះនរ:កំពុងអង្គុយសញ្ជឹងគិតម្នាក់ឯងនៅមាត់បង្អួចក្នុងបន្ទប់ក្បែរដើមផ្កាត្របែកព្រៃ នារាត្រីដ៏ស្ងាត់។សំឡេងចម្រៀងដ៏លន្លង់លន្លោចរបស់លោកតាសុិន ស៊ីសាមុត ដែលឮពីផ្ទះអ្នកក្បែររបង បកផាត់តាមរយ:វាយោមកប៉ះត្រចៀកអ្នកកម្លោះ។

i. ចិត្តមួយកម្រក្រមិនដែលប្រែប្រួល តែពុំអាចឃាត់បានចិត្តដែលផិតក្បត់ តើអូនជារុក្ខជាតិឬអ្វី? បានជាមិនរំភើបក្នុងចិន្ដា បងស្រឡាញ់ស្មើសង្ខារ សព្វថ្ងៃនៅជូនទឹកនេត្រាតែម្នាក់ឯង សែនស្ដាយចិត្តដែលស្នេហ៍អូន ដែលជាជនផិតតែនឹងក្បត់អា...គ្មានមេត្តា គ្មានមេត្តា។

ii. ដំណក់ទឹកភ្នែកដែលរលួយ ក៏ពុំអាចឃាត់បានចិត្តដែលឃ្លាតឆ្ងាយ ពាក្យដែលស្បថស្បែរពីគ្រាមុន បីដូចសុបិនក្នុងរដូវវស្សា ក្ដីគំនុំនិងក្ដីស្នេហាជម្រៅស្មើគ្នា ចិត្តកំព្រារងាតែម្នាក់ឯង សែនស្ដាយពេលកន្លងទៅ អូន

គ្មានមេត្តាបបន្តិចឡើយអូរ...ដល់រូបបង ដល់រូបបង។

iii. ស្នេហាដែលគ្មានព្រំដែននឹងឲ្យកម្រិត ប្តូរមកឲ្យជីវិតយ៉ាងខ្លោចផ្សា ជារអូវសានសល់សង្ឃឹមថាអូននឹងវិលវិញក្នុងពេលដ៏ខ្លី ទិវារាត្រី ដែលរាប់ពុំឈ្នះ ស្រឡាញ់និហស្ទប់អូនមានភាពដូចគ្នា បងសែនស្តាយ ស្តាយរង់ចាំជាច្រើនខែឆ្នាំលុះឥឡូវអូរ...ចាំជួបអូនដែលចិត្តក្បត់បង។

សំឡេងចម្រៀងលោកតាធ្វើឲ្យបេះដូងនរៈនៅពេលនេះកាន់តែពោរពេញទៅដោយសេចក្តីទុក្ខទ្វេឡើង។ នឹករលឹកដល់អនុស្សាវរីយ៍ស្នេហាគ្រាដំបូងដែលឲ្យគេឈឺចាប់រហូតមកដល់ពេលនេះ ពីឆ្នាំទៅហើយដែលគេក្លាយជាមនុស្សស្ងៀមស្ងាត់ សោះគព្រោះបែបនេះសោះៗមិនគួរណោស្រីចិត្តសាវ៉ាហ៊ានចោលបេះដូងដែលស្មោះ ទុក្ខឲ្យនៅក្រៀមស្វិតយ៉ាងនេះឡើយ។

ក្រឡេកមកទេពីវិញ មាណវីគេងមិនលក់ ស្មុគស្មាញរឿងការសិក្សាក៏ផុស storyមួយ៖

“ What can I do?” (ទេពីផុស)

“Sleep”  (បញ្ញាតប)

“ចុះបើគេងមិនលក់? ”

“បិទទូរស័ព្ទហើយបិទភ្នែកទៅ លក់ហើយ។”

“ចាំ!បងបញ្ញា”

“ឆាប់គេងទៅចឹង រាត្រីសួស្តី! ”

“ចាំ!បង សុបិនល្អ”

ពីពេលនោះមកបញ្ញាក៏ចាប់ផ្តើមឆាតជាមួយទេពីញឹកញាប់ ណាមួយទេពីជានារីស្ងៀមស្ងាត់តែរួសរាយ មិនចេះប្រកាន់ពច្រើន ឆាប់ជិតស្និទ្ធចុះសម្រុងជាមួយមនុស្សទូទៅណាស់ ណាមួយអ្នកទាំងពីរស្គាល់គ្នាក្នុងក្រុមនិពន្ធស្រាប់គ្រាន់តែមិនបានជួបមុខគ្នាផ្ទាល់។

# ៣

# ពន្លកស្នេហ៍ថ្មី

៧ខែកន្លងផុតទៅនៃការស្គាល់គ្នាជាមួយទេពី នរៈឃើងដូចជាមានសំឡេងសើចច្រើនជាងមុន៖

“សួស្តី!ទេពី”

“ចាំ!សួស្តីបងបញ្ញា”

“ញ៉ាំបាយនៅ?”

“ចាំ!រួចហើយ ចុះបងវិញ?”

“បងក៏រួចដែរ!”

“បងប្រុស”

“បាទ!ទេពី”

“ទេពីសួរបន្តិចបានទេ?”

“សួរឲ្យច្រើនក៏បាន”

“បងឯងចូលចិត្តDrama ផុសរឿងsadតែរហូតចឹងបង”

“បងចេះតែផុសទៅ អផ្សុក”

“ចម្លើយអស់សមហេតុផលទេបង”

“ការពិតបងធ្លាប់ត្រូវគេក្បត់ ហើយពេលខ្លះបងនៅនឹករឿងកន្លង”

“ទេពីមិនភ្ញាក់ផ្អើលទេ”

“ម្តេចចឹង?”

“ព្រោះសភាពបងបង្ហាញមកអស់”

“ទេពីព្វកែណាស់ណា៎ អាចដាក់កំប៉ុងជើងធូបមួយនៅផ្សាបានហើយចឹង”

“មើលបងនិយាយ”

“បងលលេងទេ”

ចេះកំប្លែងទៀត បញ្ញា អ្នកទាំងពីក៏តែងតែឆាត សារសង់គ្នាពីនេះពីនោះជាមួយគ្នាជារឿយៗ រហូតអ្នកទាំងពីមានចិត្តឲ្យគ្នាទាំងមិនដឹងខ្លួនរៀងៗខ្លួន។

“បងបញ្ញា!”

“បាទ!”

“កាលណាបងឯងឈប់Drama?”

“បងមានបានDramaណាទេពី”

“អត់ទៀតណាស់ shareចម្រៀងsadឥតល្ហែរ ទើសភ្នែកណាស់”

“គ្រាន់តែshareចម្រៀងថាគេDramaដែរកូននេះ”

“ឃើញហើយ ខូចអារម្មណ៍”

“បងសុំទោស ឈប់ហើយ”

“កុំឈប់តែមាត់ ឃើញទៀតឈប់និយាយរកហ្មង”

(មិនត្រូវជាអ្វីនឹងគ្នាផង ហ៊ានទៅគំរាមគេផងទេពីអើយទេពី ហិហិហិ)

“បាទ!អ្នកម៉ាក់តូច”

“នរណាម៉ាក់បងឯង”

“ទេពីហ្នឹង”

“បងនេះ យ៉ាប់មែន”

“ទេពីហា!”

“ចាំ!បង”

“បងចង់ផ្តល់ឱកាសឲ្យបេះដូងខ្លួនឯងបាន សាកល្បងម្តងទៀត”

“អូ!បងមានស្នេហាទៀតហើយហ៎”

“តែខ្លាចគេមិនព្រម ព្រោះបងធ្លាប់មានសង្សារហើយចឹង”

“ទេពីគិតថាមានប៉ុន្នានដង ក៏មិនខុសមិនអាក្រក់ដែរបង”

“ម៉េចចឹង?”

“ស្នេហាមិនដែលស្លាប់សូន្យដរាបណាមនុស្សនៅតែមានមនោសញ្ចេតនា។ បងមិនខុសទេ ទោះបងឆ្លងកាត់មកប៉ុន្នានដង ព្រោះបងមិនបានបោកប្រាស់មនោសញ្ចេតនានារីណាម្នាក់ឡើយ គេជាអ្នកលេងសើចបេះដូងដ៏បរិសុទ្ធរបស់បងទេតើ ដូច្នេះបងនៅតែសាកសមទទួលបានស្នេហាថ្មីដែលបរិសុទ្ធចំពោះបងជា

និច្ចៗ បងកុំសង្ស័យមណា បងនឹងជួបនារីដែលឲ្យតម្លៃចំពោះភក្តីភាពដ៏បរិសុទ្ធរបស់មិនខានៗ”

“ពូកែណាស់ទេពីបង បងឡើងលង់វាចាពៅហើយ”

“បងនេះ ចេះមកផ្ទែមរអីណា មែនហើយ! ស្អែកទេពីទៅផ្ទះនៅស្មៀមរាបជាមួយម៉ាក់ ព្រោះសាលានៅបាត់ដំបងគេសម្រាកហើយបង ខានទៅផ្ទះនៅនឹងយូរហើយ”

“មែនឬទេពី?”

“ភ្ញាក់ផ្អើលម្ល៉េះបង? ទេពីនិយាយលេងបានអី”

“បងសប្បាយចិត្តណាស់ដឹងទេ?”

“មានរឿងអីឬបង?”

“គឺជិតបានជួបមុខទេពីហើយចឹង ចង់ឃើញផ្ទាល់”

“អូ!បង ខាងក្រៅសសន្លប់ ទឹងហ្នង”

“ហាក!ម៉េចចឹងវិញ?”

“មុខអាក្រក់ពេក ហាហា!”

“ចឹងកាន់តែចង់ឃើញលឿន”

“បងនេះ ចឹងទេពីគេងហើយណា ស្អែកជិះឡានផង”

“បាទ!រាត្រីសួស្តីទេពីរបស់បង”

“ចាំ!សុបិនល្អបង”

# ៨

# ទេពធីតា

# មេត្តាមុរណកំណត់

ទេពីរៀបចំចេញដំណើរជាមួយម៉ាក់មក សៀមរាបលើកនេះយូរជាងរាល់ដង ដោយសារម៉ាក់ មានគម្រោងមករស់នៅផ្ទះចាស់វិញ ចៃដន្យសំណាង ដល់បញ្ញាវិញគឺចង់ជួប ចង់ឲ្យតែទេពីមកនៅ សៀមរាប ពេលនេះក៏បានដូចចិត្តតែម្តង។

“អរុណសួស្តី!អ្នកនាងតូច”

“ចាំ!អរុណសួស្តីបង”

“សំណាងល្អរហូតមកដល់ផ្ទះណា បងចាំផ្លូវ”

“ចាំ!អរគុណបង”

“ថៃខ្លួន បងទៅធ្វើការហើយ”

“ជម្រាបលាបង!”

នរ:ជិះម៉ូតូបណ្តើរគិតបណ្តើរថាពេលទេពីមកដល់ នឹងសុំណាត់ជួប ហើយសារភាពស្នេហ៍ដែលលាក់ ទុកជាយូរ ឆ្នាំតាមពីស្គាល់គ្នាមក បញ្ញាបានលួចស្នេហ៍ ទេពីតាំងពីពេលមាណវីស្តីឲ្យគេរឿងdrama facebook ម្ល៉េះ គេមិនដែលមាននរណាខ្វល់ពីគេ និងកែប្រែ ចំណុចមិនសមគេឡើយ។តាំងពីស្គាល់ទេពីមក នរ: ស្រស់ស្រាយ លែងគិតដល់ស្នេហាដែលក្បត់កន្លង។ រសៀលម៉ោង៣:០០នាទីនរ:សម្រាកពីការពិនិត្យឯក

សារបន្តិចក៏បើកទូរស័ព្ទ។បញ្ញាធ្វើការជាមន្ត្រីនៅមន្ទីរវិចិត្រសិល្បៈ។

"ជម្រាបសួរ!បងបញ្ញា"

"បាទ!ទេពី"

"ទេពីមកដល់សៀមរាបហើយ"

"បាទ!បងរស់បារម្ភហើយអីចឹង"

"អរគុណបង!    ចឹងទេពីទៅជួយរៀបម្ហូបម៉ាក់យាយសិនហើយ "

"ប្រយ័ត្នប្រយែងណាទេពីរបស់បង"

"ចាំ!អរគុណ បងដូចគ្នា"

ពេលនរៈមកដល់ផ្ទះភ្លាមក៏ប្រញាប់ងូតទឹកហើយទៅជួបម៉ាក់របស់កំលោះភ្លាមដើម្បី៖

"ម៉ាក់!"

"ចាំ!លោកកូន ញញឹមញញែម មានអ្វីនិយាយមក"

កម្លោះរូបស្រស់ក៏ចូលទៅឱបថើបអ្នកម៉ាកបង្ហាញកាយវិការបែបកូនក្មេងចឹងគួរឲ្យស្រឡាញ់ដែរតើ ធ្លាប់តែសោះកព្រោះ សោកសៅ ដល់មកសប្បាយខុសធម្មតា។

"យី!កូននេះ ធំហើយណា មកធ្វើដូចកូនក្មេងទៀត"

"ម៉ាក់! កូនចង់បានភរិយា"

"ក្បាលខូចណាស់យើងហ្នឹង ចឹងតើបានមកយកចិត្ត"

"មែនណាម៉ាក់ កូនក៏អាយុច្រើនហើយ ឬម៉ាក់មិនចង់បានកូនប្រសារទេ?"

"តាមតែចិត្តកូន តែមុននឹងសម្រេចចិត្ត គិតឲ្យបាន ១០០ដងណាកូន ត្រូវដឹងថាជីវិតគូមិនដូចនៅម្នាក់ឯងទេ កូនពេញចិត្តអ្នកណា ម៉ាក់ក៏ពេញចិត្ត ឲ្យតែជាក្ដីសុខ និងទំនួលខុសត្រូវរបស់កូន"

"បាទ!អរគុណម៉ាក់ បើគេយល់ព្រម កូននែនាំឲ្យម៉ាក់ស្គាល់ៗ"

អ្នកកំលោះយើងបានសម្រេចចិត្តណាត់ធីតាយើងជួបស្នេហ៍ព្រឹកនៅហាងកាហ្វេមួយដែលមានសៀវភៅជាច្រើន ដោយដឹងថាទេពីចូលចិត្តសៀវភៅ ម៉ោង៩ព្រឹកនរៈរូបសង្ហាក៏រៀបចំខ្លួនសាមញ្ញធម្មតាទៅចាំមាណវីជាស្រេច សាមញ្ញបែបណាក៏នៅតែសង្ហាព្រោះចំណេះដឹង និងកាយវិការសុភាពបុរសរបស់គេៗ

"ជម្រាបសួរ!បងបញ្ញា"

អ្នកកម្លោះឡើងស្រឡាំងកាំងនឹងសម្រស់តូចតន់ ជាមួយកាយវិការលើកដៃសំពះដ៏ទន់ភ្លន់រួមជាមួយ សំឡេងសែនស្រទន់របស់នាងតូច

"បង!បងបញ្ញា!"

"បាទ!បាទ! ជម្រាបសួរទេពី អញ្ជើញអង្គុយ"

អ្នកកម្លោះយើងប្រញាប់ទាញកៅអីជូនធីតាស្រី

"ចាំ!អរគុណបង សុំទោសដែលឲ្យបងចាំយូរ ទេពីខាន មកយូរ ឡើងវង្វេងផ្លូវ"

"បាទ!មិនយូរទេ ទេពីទៀងម៉ោងល្អណាស់ មិនឲ្យ លើសសូម្បីតែ១នាទី"

"ថ្ងៃនេះបងអត់ធ្វើការទេ?"

"ទេពីសែនស្រស់សោភាម្ល៉េះទេពៅ"

"ចាំ! បងឆ្លើយខុសសំណួរហើយ"

"បាទ!បងអត់ធ្វើការទេថ្ងៃនេះ"

"ចាំ!បង"

ទេពីអៀនមុខឡើងក្រហម រួមជាមួយសំ លៀកបំពាក់អាវយឺតពណ៌ផ្កាត្រសក់ព្រៃ កាន់តែឲ្យ អ្នកកម្លោះយើងទប់លេះដូងមិនស្នេហ៍មិនបាន

"ទេពី!"

"ចាំ!បង"

"ទេពី!ផ្តល់ឱកាសឲ្យបងបានទេ?"

គេមកដល់លតជង្គង់ក្បែរតុស្រស់ស្រីដៃកាន់ជាមួយសៀវភៅមួយក្បាលនិងផ្កាត្របែកព្រៃមួយបាច់ល្មមមាណវីរៀនរឹងខ្លួនមិនរួចបានត្រឹមបើកភ្នែកធំៗ

"ទេពី!ថាស្នេហាមិនដែលស្លាប់សូន្យដរាបណាមនុស្សនៅតែមានមនោសញ្ចេតនា។ បងមិនខុសទេ ទោះបងឆ្លងកាត់មកប៉ុន្មានដង ព្រោះបងមិនបានបោកប្រាស់មនោសញ្ចេតនានារីណាម្នាក់ឡើយ គេជាអ្នកលេងសើចលេះដូងដ៍បរិសុទ្ធរបស់បងទេតើ ដូច្នេះបងនៅតែសាកសមទទួលបានស្នេហាថ្មីដែលបរិសុទ្ធចំពោះបងជានិច្ច។ តើទេពីធ្វើជានារីម្នាក់នោះសម្រាប់បងបានទេ?"

ទេពី និងបញ្ញាជាមនុស្សត្រង់ៗមិនចេះអួសអួនយូរដូចគេផ្សេង តូចតន់តបមួយៗ៖

"ទេពី!អត់រើសអើងអ្វីចំពោះបងទេ រយៈពេល៣ឆ្នាំមកនេះ ធ្វើឲ្យទេពីមិនមានអ្វីប្រកែកនឹងបងទេ"

នរៈរំភើបនឹងសម្តីស្រស់ស្រី ព្រោកមកជាមួយពាក្យ៖

“បងអរគុណណាស់ដែលទេពធីតាព្រមមេត្តាដល់បុរសកំសត់ម្នាក់នេះ សន្យាថែបេះដូងជូនអូនតែម្នាក់ៗ”

ចន្ទ បូណ៌មី

# ៥

# ក្រអោលល្មើចាស់

ពេលវេលាប្ដូរពីអ្នកស្គាល់គ្នាក្នុងក្រុមមកជាសង្សានិងគ្នា៦ខែយ៉ាងឆាប់រហ័ស។ អ្នកទាំងពីរគាន់តែផ្អែមល្ហែម យល់ចិត្ត មិនដែលឈ្លោះប្រកែកគ្នាទេ ពួកគេបែងចែកការងារ និងពេលវេលាសម្រាប់គ្នាទៅវិញទៅមកបានល្អណាស់។ ប៉ុន្តែយើងដឹងហើយថាចានក្នុងរាវទោះអ្នកប្រើថ្នមយ៉ាងណានៅតែគេចមិនផុតពីការទង្គិចគ្នាជាដាច់ខាត គ្រាន់តែតិចឬខ្លាំងអាស្រ័យលើមនុស្សនោះប៉ុណ្ណោះ។ ស្រមោលស្នេហាចាស់របស់បញ្ញាកំពុងត្រលប់មកលងបន្លាចដល់បញ្ញាម្ដងទៀតហើយ បន្ទាប់ពីទុកបញ្ញាចោលអស់រយៈពេលបីឆ្នាំ។

"បងដាក់ In a relationship ស្របពេលអូនបែកពីគេ" (កែវ រលក្ខណ៍)

កែវ រលក្ខណ៍ជានរណា? រលក្ខណ៍ជាអតីតសង្សាររបស់បញ្ញាកាលពី៣ឆ្នាំមុន ដែលគេបានក្បត់ពីបញ្ញាទៅមានអ្នកថ្មី ទុកឲ្យបញ្ញាឈឺចាប់ក្រំគ្រាម្នាក់ឯងជាយូរ ពេលនេះគេក៏ត្រលប់មកវិញ ព្រោះលែងមានអ្នកត្រូវការគេ។

"បាទ! សំណាងល្អប្អូន"(បញ្ញា)

"បងបំភ្លេចអូនហើយឬ?"(រលក្ខណ៍)

“មិនដែលបំភ្លេចទេ”(បញ្ញា)

“បងនៅស្រឡាញ់អូនដដែលមែនទេ?”(វលក្ខណ៍)

“គ្រាន់តែមិនដែលចងចាំ”(បញ្ញា)

“អូនសុំទោសដែលទុកបងចោល”(វលក្ខណ៍)

នរ:យើងក៏ឈប់តប ក្រឡេកមកមើលមាណាវីដ៏ទន់ភ្លន់របស់យើងវិញបានឃើញខមិនឆ្លើយឆ្លងរបស់សង្សារជាទីស្រឡាញ់ជាមួយស្រីដទៃបែបនេះ ភាំងស្មារតី បេះដូងស្ទើតែប្រេះបែកភ្លាមៗ ទេពីលែងមានអារម្មណ៍ធ្វើការបន្ត ក៏ចេញមកផ្ទះមុនម៉ោងកំណត់ៗមកដល់ផ្ទះបើកទូរសព្ទ គាប់ជួនបញ្ញាក៏ទូរសព្ទមកល្មម៖

“សួស្តី!អូនសម្លាញ់ អូនមិនស្រួលខ្លួនឬពៅ បានចេញពីធ្វើការលឿន?”

“ចាំ!អូនមិនបានកើតអីទេបង”

“ប្រាប់បងមក បងបារម្ភ”

“អូនវិលមុខបន្តិចបន្តួចទេបង សម្រាកបន្តិចក៏បាត់”

នរ:ដឹងថាទេពីមិនសប្បាយចិត្ត មានរឿងលាក់បាំងក៏សួរ៖

“បងធ្វើអីខុសឬ ទើបពៅមិនស្រួលចិត្តបែបនេះទេ?”

“អ្នកដែលខមិនជាមួយបង ជាអ្វីនឹងបង?”

“មកពីរឿងហ្នឹងមែនទេ? បងនេះយ៉ាប់ណាស់ ឲ្យអូនឈឺ បងសុំទោសណាអូនសម្លាញ់ “

“ឆ្លើយសំណួរអូនមកបង?”

“អូនកុំយល់ច្រឡំណា គេជាបិសាចដែលទៅចោលបងជាយូរ បងមិនដឹងថាគេចង់មកនេះគោលបំណងអីទេពៅ”

“គេត្រលប់មកវិញហើយ បងគិតបែបណា?”

“ក្មេងខូច! មើលសួរបង បងមានតែអូនម្នាក់ទេ គេលែងមានតម្លៃក្នុងភ្នែកបងជាយូរមកហើយពៅ”

“បងនៅអាណិតគេឬ?”

“អត់ទេ! បងឈប់ហើយ បងតបជាការគួរសមក្នុងនាមជាអ្នកស្គាល់គ្នាទេ ពៅទុកចិត្តបងណា”

“ចាំ!បងមិនអីទេ លួងអូនបន្តិចមកចឹង”

“ក្មេងខូច បងអានសៀវភៅឲ្យស្តាប់ណា បិទភ្នែកគេងទៅ បងនៅជិតអូន”

“ចាំ!បង”

មាណវីល្មើយនឹងការងារផង ហត់ចិត្តផងក៏លង់លក់យ៉ាងរហ័ស ណាមួយក៏នាងមិនចូលចិត្តនិយាយដេញដោលច្រើន។

រឿងរ៉ាវជីវិតគូរអ្នកទាំងពីមិនចប់ត្រឹមនេះទេ វលក្ខណ៍មាននាមជាបិសាចដែលបញ្ហាដាក់ឲ្យ នៅតែមករញ៉េរញ៉ៃមិនឈប់។

នាងតែងតែshareបទចម្រៀងហើយtagឲ្យបញ្ហារាល់ថ្ងៃ មិនតែប៉ុណ្ណោះ ឆាតមកផង សារមកតាមtelegramផង ឥតល្ហែរ ចុះបើអ្នកជាទេពីវិញ មានអារម្មណ៍បែបណា នៅពេលគេមកបែបនេះជាមួយបុរសដែលយើងស្រឡាញ់? ចុះអ្នកដែលជាFriendsក្នុងfacebookជាច្រើនឃើញយល់យ៉ាងណាចំពោះនាងជានារីដែលមកក្រោយគេ? មិនគិតថានាងដណ្តើមរបស់គេទេឬ?នៅសុខៗអ្នកចាស់ក៏លេចមុខមកបែបនេះ?ទោះនាងជានារីចិត្តធូន់យ៉ាងណាក៏ដោយ មិនខ្វល់ពីអ្នកដទៃយ៉ាងណា តែជឿនាងមានមនោសញ្ចេតនាខ្ពស់ យ៉ាងណាក៏ពិបាកណាស់ហើយ។

វលក្ខណ៍តែងតែឆាតមកបញ្ញា ចំណែកបញ្ញាចិត្តមិនដាច់តបតែរហូតដែរ តែបញ្ញាមិនដែលលាក់បាំងនារីជាទីស្រឡាញ់របស់ខ្លួនទេ។គេតបដោយរាប់អាន នៅឲ្យតម្លៃ មិនបាននៅស្រឡាញ់ទេ តែចិត្តជាស្រីនាងនៅតែពិបាកទទួលយក នរៈបានថតអ្វីដែលវលក្ខណ៍ផ្ញើមកគេតាមtelegramឲ្យទេពីដើម្បីបង្ហាញការទុកចិត្ត។ នាងស្រីចិត្តបិសាច ផ្ញើរូបភាពឈឺមករំរួយទាមទារចំណាបចំណាប់អារម្មណ៍ពីបញ្ញា ផ្ញើបទចម្រៀងផង ផ្ញើសំឡេងមកផង។

“បងមិនដឹងថាគេមានគោលបំណងអ្វីឲ្យពិតប្រាកដទេ?”(បញ្ញា)
“គេចង់បានបងទៅវិញហើយ បងដឹងទេ”(ទេពី)
“គេពិសពុលណាស់! សាហាវដូចបិសាច គ្មានថ្ងៃអាចទេពៅ មិនស្មើទេពធីតាបងទេ ទាំងទន់ភ្លន់ ទាំងមានហេតុផល និងឲ្យតម្លៃបង រកឯណាបានមនុស្សស្រីដូចអូន”(បញ្ញា)
“បងដឹងអត់! អូនល្ងើយណាស់ ចិត្តអូនជាមនុស្សមានសាច់ មានឈាម មិនមែនដុំថ្មទេ យ៉ាងណាអូននៅតែធ្វើចិត្តមិនបាន នៅពេលមានរឿងបែបនេះ”

"បងសុំទោស! បងសុំទោសពៅព្រលឹមមាសបង"

ក្នុងចិត្តនរៈស្ទើរប្រេះបែកជាពីភ្លាមៗ នៅពេលឃើញមាណវីស្រក់ទឹកភ្នែក តាមពីស្គាល់មកគេមិនដែលឃើញតួចស្រីយំបែបនេះទេ បើអាចហោះបានគេនឹងស្ទុះទៅឱបកាយស្រីជាប់ដើមទ្រូង មិនឲ្យនាងល្វើយបែបនេះទេ។ ទេពីជានារីម៉ឺងម៉ាត់តែទន់ភ្លន់ណាស់ ពិសេសរឿងស្នេហា នាងសុភាពរាបសារ មិនចេះលាក់ពុតបង្ហាញត្រង់ៗ ពិសេសជាមួយមនុស្សដែលនាងគោរព ស្រឡាញ់។មាណវីលែងស្តីជាមួយបញ្ញា

"អូនសម្លាញ់! បងពិតជាសុំទោស ដែលឲ្យអូនយំ ពៅនិយាយរកបងមក កុំស្ងាត់ចឹង បងភ័យណាស់"

"បងនៅស្តាយគេឬ? បងចង់ត្រូវគ្នាជាមួយគេវិញឬ? បងឈប់កុហកអូន ឈប់កុហកខ្លួនឯងតទៅទៀតទៅប្រាប់អូនត្រង់មក អូនមិនខឹងបងទេ"(ទេពី)

"ពៅសម្លាញ់!បងស្រឡាញ់អូនណាស់ គ្មាននរណាជំនួសអូនបានទេ គេមកជារឿងគេ បងមិនបានស្រឡាញ់បិសាចដូចគេទេ បងមានតែអូន បងមិនស្តាយដែលមានអូន មានតែសំណាងបាននារីដែលល្អដូចពៅ"(បញ្ញា)

“បានហើយ!បងឈប់កុហកអូនទៅ ទៅឲ្យឆ្ងាយពីអូនទៅ ទៅ”(ទេពី)

“បងសុំទោស! បងនៅជាមួយអូន ស្រឡាញ់អូនតែម្នាក់ស្ដាប់បងណា បងមិនពាក់ព័ន្ធជាមួយគេតទៀតទេ បងលុបគ្រប់យ៉ាងណា ណាពៅណា បងសុំទោស” (បញ្ញា)

ទេពីយំរហូតដល់គេងលក់លែងតបស្ដី បញ្ញាបារម្ភអាណិតមាណវីខ្លោចចិត្តព្រោះភាពមិនដាច់ស្រឡះរបស់គេ គេក៏ទៅលុបគ្រប់យ៉ាង មិនឲ្យស្រីចិត្តបិសាចមកទាក់ទងបានទៀតទេ។

ចន្ទ បូរណ៍មី

# ៦

# ស្នេហ៍នៅតែបរិសុទ្ធ

ទេពីបានសម្រាកពីការងារមួយខែដោយសារតែនាងចាប់ផ្ដើមឈឺ នរៈរូបសង្ហាមិននៅយូរក៏ដាក់ច្បាប់ការងារ ឡើងមកបាត់ដំបងមើលតូចតន់ស្រី នាំទាំងមីងលក្ខណាមកជាមួយផងដែរ។គ្រួសារទេពីទទួលដោយយកចិត្តទុកដាក់ចំពោះគ្រួសារបញ្ញានិងម្ដាយ៖

“ជម្រាបសួរ! អញ្ជើញចូលក្នុងអ្នកបង និងក្មួយ”(មីងសុជាតិ) ជាម្ដាយរបស់ទេពី ពូកែធ្វើម្ហូបណាស់

“បាទ!អរគុណមីង”

“ទេពីសុខភាពយ៉ាងណាហើយ?”(ម្ដាយបញ្ញា)

“មួយអាទិត្យនេះ ទេពីនៅតែបន្ទប់ ញាំមិនសូវបានទេអ្នកបង ព្រឹកមិញក៏ក្ដៅខ្លួនខ្លាំង”(ម្ដាយទេពី)

“តើអាចសុំទៅមើលក្មួយទេពីបានទេអ្នកបង”(មីងលក្ខណា)

“ចា៎!អញ្ជើញឡើងទៅខាងលើ បន្ទប់ខាងស្ដាំដៃ ខ្ញុំទៅរៀបបាយជូន”(មីងសុជាតិ)

បញ្ញាបានឡើងទៅមើលទេពីដល់បន្ទប់ជាមួយម្ដាយតែនាងគេងលក់មិនដឹង អ្នកមីងក៏ចុះមកជជែកនឹងគ្រួសារទេពីវិញ ទុកឲ្យនរៈរូបសង្ហារ អង្គុយមើលមាណ

រីដោយក្ដីអាណិត និងខឹងចំពោះខ្លួនឯងដែលជាដើមហេតុឲ្យមាណវីធ្លាក់ខ្លួនឈឺ ទេពីក៏បើកភ្នែកមក ឃើញនរៈនៅនឹងមុខ៖

“ចេះយល់សប្តិទៅកើតដែរណ៎ះឃើញនេះ”(ទេពី)

“មិនបានយល់សប្តិទេ គឺបងណារ៉ាអូន”(បញ្ញា)

ស្រស់ស្រីស្ទុះក្រោកមកចាប់ដៃមើល ដើម្បីបញ្ជាក់ឲ្យច្បាស់

“បងមែន បងមកពីកាលណា?”(ទេពី)

“នឹកអូនណាស់ បងសុំទោស”(បញ្ញា)

នរៈទាញកាយស្រី មកឱបថ្នមៗយ៉ាងយកចិត្តទុកដាក់

“ដាក់ហុសបងឲ្យពៅឈឺ ពីពេលនេះទៅបងនិងនៅជិតអូនរហូត មិនឲ្យពៅទឹកភ្នែកដោយសារបងទៀតទេ”

“អូនក៏សុំទោសដែលនិយាយមិនពិរោះដាក់បង ការពិតហេតុអីយើងត្រូវឈ្លោះគ្នាព្រោះមនុស្សមិនល្អចំពោះយើង យើងខ្វល់ពីអ្នកដទៃ មិនបានខ្វល់ពីក្តីសុខយើងខ្លួនឯង គេគ្មានឥទ្ធិពលអីមកលើយើងទេ គេមិនមែនអ្នកកំណត់ឲ្យយើងទេ យើងមានរឿងអីត្រូវឈ្លោះដោយសារមនុស្សអត្តានិយម”

“ពិតណាស់! បងមកប៉ះប៉ូវសងអូនវិញហើយណាសងពៅគ្រប់យ៉ាងណាព្រះនាងតូច”

ចាំណាបងប្អូនជីវិតគូមិនមែនជួបម្តងក៏សមបំណងទេ ហើយជីវិតគូក៏មិនមែនសុខរហូតដោយគ្មានឧបសគ្គដែរ។ សំខាន់ណាស់ ការមិនបោះបង់គ្នាស្តាប់គ្នាដោយមានហេតុផល ទុកចិត្តគ្នា ពិសេសត្រូវរឹងមាំ ច្បាស់លាស់ចំពោះគោលដៅជីវិតគូយើង កុំឲ្យអ្នកដទៃមានឥទ្ធិពល និងអាចមកកំណាត់ផ្លូវជីវិតស្នេហាយើងឲ្យសោះ។ រឿងអតីតកាលនរណាក៏មាននរណាក៏ធ្លាប់ខុសដែរ តែសំខាន់យើងកុំប្រកាន់មាំជាមួយរឿងកន្លង កុំយកអតីតកាលមកប្រៀបធៀបបច្ចុប្បន្ន ឲ្យក្លាយជារនាំងក្តីសុខជីវិតពិតបច្ចុប្បន្នយើងបាន។

នរ:និងមាណវីបានរៀបការជាមួយគ្នា ចាប់ដៃគ្នារហូតបានបើកហាងកាហ្វេនៅសៀមរាប និងបាត់ដំបងមានបណ្ណាគារ និងបណ្ណាល័យអានសៀវភៅដោយមិនគិតប្រាក់ជាច្រើនកន្លែង។ នរ:នៅគ្រប់គ្រងហាង និងធ្វើអ្នកនិពន្ធឯករាជ្យតាមក្តីស្រម៉ៃរបស់គេ ចំណែកមាណវីទេពីវិញនៅបន្តការងារខាងក្រៅដដែល ព្រោះនាងចង់ជួយសង្គមតាមរយ:ការងារនាងដដែល។

# ៧

# រសនៃស្នេហាពិត

គេត្រឡប់ឃើញបរិវេណផ្ទះថ្មធំល្វម ពោរពេញទៅដោយធម្មជាតិជាច្រើន ពិសេសផ្កាដែលមានពណ៌ស្វាយ ស និងចម្រុះពណ៌យ៉ាងច្រើន រិតតែពិសេសនោះគឺដើមផ្កាត្របែកព្រៃជុំវិញបងផ្ទះទាំងក្នុងនិងក្រៅតែម្តង សបញ្ជាក់ឲ្យឃើញថាទេពីស្រឡាញ់ផ្កាត្របែកព្រៃពណ៌ស្វាយណាស់ បានជានរៈរូបសង្ហារបញ្ញា ចំណាយពេលតុបតែងលម្អសុទ្ធតែធម្មជាតិសម្រាប់ភរិយាយ៉ាងនេះ។ឆ្នាំនេះមាណវីសម្រាកពីការងារឯកជន និងរដ្ឋ មកប្រើជីវិតនៅផ្ទះ ធ្វើម្ហូបស្រាចបន្លែ សួនផ្កាយ៉ាងសាមញ្ញជាមួយគ្រួសារ ។ចំណែកការរកស៊ីដែលគ្រប់គ្រងដោយបញ្ញាក៏កាន់តែជោគជ័យព្រោះមានភរិយាដ៏ឈ្លាសវៃនៅពីក្រោយ បញ្ញាក៏ដើរមកពីក្រោយហើយឱបមាណវីដែលកំពុងឈរមើលផ្កាត្របែកព្រៃយ៉ាងយកចិត្តទុកដាក់ហើយពោល៖

"ប្រពន្ធសម្លាញ់! បងពិតជាអរគុណអូនណាស់"

"លោកប្តី!អរគុណអូនរឿងអី?"

"អរគុណទេពធីតាដែលបានផ្លាស់ជីវិតបុរសកំសត់ដែលគ្មានគោលដៅអ្វី មកជាមនុស្សមានមុខមាត់ក្នុងសង្គម និងជោគជ័យក្នុងជីវិតដល់សព្វថ្ងៃ"

“អូនមិនបានធ្វើអ្វីទេ មកពីបងខ្លួនឯងណាលោកប្ដី ជាភរិយាត្រូវតែចាំគាំទ្រ ជម្រុញលើកទឹកចិត្តពីក្រោយស្វាមីជានិច្ចណាលោកប្រុសម្ចាស់”

នរៈយកដៃអង្អែលសក់ដ៏រលោងរបស់ភរិយាថ្នមៗ ហើយឱនថើបថ្ពាសមាណវីយ៉ាងផ្អែមល្ហែម តែខណៈនោះទេពីរកកលំចង់ក្អួតក៏រត់ទៅបន្ទប់ទឹកយ៉ាងលឿនបញ្ញាឯណោះ ភ័យឡើងក្រហមមុខរអស់រត់តាមប្រពន្ធពីក្រោយ៖

“ពៅកើតអីៗ ម្ដេចអូនក្អួតយ៉ាងនេះ អូនញុំាអីខុស? អូនឈឺក្រពះឬ?តោះទៅឲ្យគ្រូពេទ្យពិនិត្យ?”

“លោកប្ដី!មួយៗណា ប្រពន្ធបងមិនកើតអីទាំងអស់”

“មិនកើតអីម្ដេចបានពៅ? តោះបងជូនអូនទៅពេទ្យ”

“ស្ដាប់ណាលោកប្ដី ទេពីកំពុងចាញ់កូន”

“ថាម៉េច...! អូនមានកូនហើយ?»

«ចាស!» ទេពីឆ្លើយតិចៗ

«យេ! បងជិតក្លាយជាប៉ាគេហើយ” នាយយើងលើកបីប្រពន្ធថ្នមៗ ហើយសួរនាង៖

“ម្ដេចទើបតែប្រាប់បងពេលនេះ?”

“អូនចាំប្រាកដសិន អូនមានផ្ទៃពោះ៤សប្ដាស៍ហើយ”

"អរគុណអូនសម្លាញ់ អូនមិនត្រូវធ្វើអីទេ ទុកការងារឲ្យបងធ្វើទាំងអស់ កុំឲ្យអូនហត់ និងប៉ះពាល់ដល់កូនយើង"

"ហិហិហិ!បងនេះ"

នរៈអង្គុយចុះឱបកាយប្រពន្ធសំណព្វលេះដួងថ្នមៗ មិនហ៊ានឱបខ្លាំងខ្លាចកូនថប់ដង្ហើម ហិហិហិ។

"បងអរគុណព្រះនាងតូចគ្រប់យ៉ាងសម្រាប់សុភមង្គលមួយនេះ តែងតែនៅជាមួយបងគ្រប់កាលៈទេសៈ ទុកចិត្ត មិនដែលមើលងាយ មិនបោះបង់បងចោល បងស្រឡាញ់អូនណាស់ប្រពន្ធសម្លាញ់"

"អូនក៏អរគុណបងសម្រាប់គ្រប់យ៉ាង ការឲ្យតម្លៃ ការមើលថែ ភាពកក់ក្ដៅ និងស្នាមញញឹមរាល់ថ្ងៃ"

នរៈថើបពោះមាណវីយ៉ាងមានសុភមង្គល សំឡេងចាបយំ ចេប!ចេប! និងស្រទាប់ផ្កាត្របែកព្រៃធ្លាក់ចុះមកស្គុះស្គាយ ហាក់ទេវតាបាចផ្កាប្រទានពរជ័យ និងចូលរួមសាទរនៅសុភមង្គលដល់គូស្នេហាពិតរួមទាំងbabyតូចផងដែរ។

រសនៃស្នេហាពិតគឺមានសុភមង្គលបែបនេះឯងណា ឈ្លោះខ្លះ ផ្អែមខ្លះតែមិនបោះបង់គ្នា រាល់បញ្ហាត្រូវជជែករកដំណោះស្រាយរួមគ្នា កាន់ដៃគ្នាតស៊ូរហូតទទួលបានរសនៃសុភមង្គលបែបនេះទើបហៅថាស្នេហាពិតដែលច្បាស់លាស់។

(ចប់)

អរគុណជាថ្មីម្ដងទៀតដែលបានចំណាយពេលវេលាអានស្នាដៃមួយនេះតាមពីដើមរហូតដល់ចំណុចចុងបញ្ចប់នៃរឿង។ប្រសិនបើមិត្តអ្នកអានមានជាមតិរិះគន់ក្នុងន័យស្ថាបនាចំពោះស្នាដៃមួយនេះ ខ្ញុំសូមស្វាគមន៍ដោយក្ដីសោមនស្សរីករាយជានិច្ច ។ឲ្យខ្ញុំបានកែលម្អនូវចំណុចខ្វះខាតទាំងឡាយ ដើម្បីឲ្យខ្ញុំអាចបម្រើដល់អារម្មណ៍របស់មិត្តអ្នកអានកាន់តែប្រសើរថែមទៀត។ សូមទំនាក់ទំនងមកអ្នកនិពន្ធតាមរយៈ៖

Facebook page : ឧទ្យានទឹកខ្មៅ/garden peom

ឬតាមរយ:

Facebook : Reaksa Khon (ចន្ទបូណ៌មី)

# ស្នាដៃដែលបានចេញផ្សាយហើយ

